

# ពូជពោត សជ័យ

## Sar Chey



វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា
Cambodian Agricultural Research and Development Institute

## ប្រវត្តិរបស់ពូជ

ពូជពោត "**សជ័យ**" ត្រូវបានរំដោះដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា នាចុងឆ្នាំ២០០៦ បន្ទាប់ពីបានធ្វើការពិសោធន៍អស់រយៈពេលប្រាំមួយរដូវ (បីឆ្នាំ) កន្លងមក។ ពូជនេះមានប្រភពដើមចេញពីស្រទ្បាយ S-99TL WQ-HG-AB របស់វិទ្យាស្ថានស៊ីមីត (CIMMYT) ដែលស្ថិតនៅប្រទេសម៉ិចស៊ិចកូ ហើយជាប្រភេទពូជដែលមានប្រូតេអ៊ីនខ្ពស់។

## លក្ខណៈពិសេសៗរបស់ពូជពោត "សជ័យ"

<u>លក្ខណៈរូបសាស្ត្រ</u>

ពូជពោត "**សជ័យ**" មានលក្ខណៈដើមដងរឹងមាំ ស្លឹកមានពណ៌ខៀវចាស់ ហើយដុះលូតលាស់យ៉ាងលឿនបន្ទាប់ពីដាំបាន ១៥-២០ ថ្ងៃ។ ប្រព័ន្ធឫសមានការដុះលូតលាស់យ៉ាងខ្លាំង មានតួនាទីទប់ដើមមិនឲ្យដួលរលំដោយសារខ្យល់ និងនៅពេលដើមចាប់ផ្ដើមស្ងួតឬងាប់។ ដើមមានកម្ពស់ជាមធ្យមពី ១.៥០ ម៉ែត្រ ទៅ ២.៣០ ម៉ែត្រ។ កំពស់ផ្លែពីដីគឺពី ០.៧០ ម៉ែត្រទៅ ១.២០ ម៉ែត្រ។ ផ្លែមានរាងទ្រវែងប្រវែងពី ១៥ សង់ទីម៉ែត្ររហូតដល់ ២៥ សង់ទីម៉ែត្រ។ គ្រាប់មានពណ៌សរាងដូចធ្មេញកោងរលោងផ្នែកខាងខ្នង ចំនួនជួររបស់គ្រាប់ក្នុងមួយផ្លែមានពី ១៤-១៨ ជួរ នឹងទំងន់ ១០០០ គ្រាប់ស្មើនឹង ២៦៦ ក្រាម។

<u>ទិន្នផល</u>

ពូជពោត "**សជ័យ**" អាចផ្ដល់ទិន្នផលជាមធ្យម ៤,០ តោន ក្នុងមួយហិកតា ប៉ុន្តែក្នុងលក្ខខណ្ឌល្អអាចផ្ដល់ផលរហូតដល់ ៩,០ តោន ក្នុងមួយហិកតា។

ការប្រើប្រាស់ពូជ

ការដាំដុះពូជពោត "**សជ័យ**" លើផ្ទៃដីមួយហិកតាត្រូវការពូជពី ៣០ ទៅ ៣៥ គីឡូក្រាម (ដាំ ២-៣ គ្រាប់/គុម្ព)។

## វិធីសាស្ត្រដាំដុះ

គេអាចធ្វើការដាំដុះដំណាំពោតបានពេញមួយឆ្នាំ ដោយការបុកដាំ ការដាំជាជួរ ឬដាំតាមចង្អូរដូចតារាងខាងក្រោម។

| ចន្លោះជួរ | ចន្លោះគុម្ព (ស.ម) | |
|---|---|---|
| | ១ ដើម/គុម្ព | ២ ដើម/គុម្ព |
| ៦៥ | ៣០ | ៦០ |
| ៧០-៨០ | ២៥ | ៥៥ |
| ៨៥-៩៥ | ២០ | ៤០ |

មុនពេលដាំត្រូវយកគ្រាប់ពូជមកត្រាំទឹកឲ្យបានពី ៤-៦ ម៉ោងដើម្បីឲ្យគ្រាប់រីកឆាប់ដុះ (តំបន់ដែលមានទឹកគ្រប់គ្រាន់) ដោយដាក់គ្រាប់ក្នុង



មួយរណ្ដៅពី ២-៣ គ្រាប់ និងជម្រៅពី ២-៤ ស.ម។ នៅរដូវប្រាំងត្រូវធ្វើការស្រោចស្រពដីឲ្យបានជោគក្រោយពេលដាំ។ ចំពោះតំបន់ដាំដុះដែលអាស្រ័យទឹកភ្លៀង យើងត្រូវដាំគ្រាប់ស្ងួតដោយមិនចាំបាច់ត្រាំទឹកទេ។ ការកាត់រំលោះដើម គឺអាចធ្វើនៅពេលកូនពោតមានអាយុបាន ១០ ទៅ ១៥ ថ្ងៃដោយទុកតែ ១ ដើមក្នុងមួយគុម្ព និងធ្វើការសម្អាតស្មៅឲ្យស្អាត ជៀសវាងការប្រជែងស្រូបយកជីជាតិពីដំណាំ ដែលធ្វើឲ្យដំណាំក្រិន មិនសូវលូតលាស់ និងផ្ដល់ផលតិច។

## ការដុះលូតលាស់

ការធ្វើដីបានផុសល្អ ដីមានជីជាតិ សំណើមគ្រប់គ្រាន់ និងធាតុអាកាសអំណោយផលនោះ ក្រោយពីដាំបានចំនួន ៥-៦ ថ្ងៃគ្រាប់ចាប់ផ្ដើមដុះពន្លកទូលដីមកខាងលើ និងក្រោយពីដាំបានចំនួន ១៥-២០ ថ្ងៃ ការដុះលូតលាស់របស់ពូជនេះប្រព្រឹត្តទៅយ៉ាងលឿន និងមានកម្ពស់ពី ៥០-៧០ សង់ទីម៉ែត្រ ដើមថ្លោស ស្លឹកឡើងពណ៌បៃតងស្រងាត់។ ពូជនេះចាប់ផ្ដើមចេញផ្កាឈ្មោលនៅពេលបានអាយុកាល ៥០-៥៣ ថ្ងៃក្រោយពីដាំ និងចេញផ្កាញីនៅពេលបានអាយុកាល ៥៣-៥៥ ថ្ងៃក្រោយពីដាំ និងចាប់ផ្ដើមទុំនៅរយៈពេល ៥៥-៦០ ថ្ងៃក្រោយពីចេញផ្កាញី។





## ការប្រើប្រាស់ជី

ការប្រើប្រាស់ជីតាមបច្ចេកទេស និងត្រឹមត្រូវតាមពេលវេលាធ្វើឲ្យដំណាំដុះលូតលាស់ល្អ ទទួលបានទិន្នផលខ្ពស់។ ជីដែលអាចប្រើប្រាស់គឺ អាសូត ផូស្វ័រ និងប៉ូតាស្យូម ($N; P_2O_5; K_2O$)។ កម្រិតនៃប្រើជី

អាចប្រែប្រួលទៅតាមប្រភេទដី។ ការប្រើប្រាស់ជីចែកចេញជាបីដំណាក់កាល គឺដាក់ទ្រាប់បាតមុនពេលដាំ ដោយប្រើប្រាស់ជីអាសូត (៥០%) ផូស្វ័រ និងប៉ូតាស្យូម (១០០%) ចំណែកអាសូតនៅសល់ (៥០%) ប្រើសម្រាប់ដាក់បំប៉នចំនួនពីរលើកទៀត គឺលើកទី១ (២៥%) ក្រោយពីដាំបាន២០-២៥ ថ្ងៃ និងបំប៉នលើកទី២ (២៥%) ក្រោយពីដាំបាន ៤០-៤៥ ថ្ងៃ។ ការដាក់ជី គឺយើងត្រូវដាក់ឲ្យឆ្ងាយពីគល់ពី ១០-១៥ ស.ម រួចពូនដីលប់ឲ្យជិត ដើម្បីទប់គល់ពោតផង និងការពារជីមិនឲ្យបាត់បង់តាមរយៈការហើរទៅក្នុងបរិយាកាស និងការហូរច្រោះដោយសារទឹក។

| ជី | កម្រិតជីទៅតាមប្រភេទដី (គក្រ/ហាត) | | | | |
|---|---|---|---|---|---|
| | ដីខ្សាច់ (ព្រៃខ្មែរ-ប្រទះឡាង) | ដីឥដ្ឋ (កំពង់សៀម) | ដីក្រហម (ឡាបានសៀក) | ដីកណ្ដោង (ទួលសំរោង) | ដីល្បាប់ (កៀនស្វាយ) |
| អ៊ុយរ៉េ | ១២៤ | ១៧៤ | ១៧៤ | ១៧៤ | ១៥០ |
| ដេ អា ប៉េ | ៩៥ | ១០៧ | ១០៧ | ១០៧ | ៨៥ |
| ប៉ូតាស្យូម | ៣៧ | ៤៥ | ៤៥ | ៣៧ | ៥៤ |

## ការប្រមូលផល

គេអាចប្រមូលផលពោត នៅពេលដើមពោតចាប់ផ្ដើមប្រែពណ៌ពីសំបកក្ដាមទៅលឿងស្ងួត ឬងាប់ដើម សំបកផ្លែមានពណ៌លឿងស្ងួតហើយស្រួយ សក់ពោតឡើងស្ងួត ឬសំគាល់មួយផ្នែកទៀតនៅលើគល់របស់គ្រាប់ឡើងពណ៌ប្រផេះ គឺនៅពេលពោតបានអាយុកាលពី ១០៤-១១២ ថ្ងៃបន្ទាប់ពីដាំ។ ការយឺតយ៉ាវក្នុងការ ប្រមូលផលនៅរដូវភ្លៀងធ្លាក់ជោគជាំ អាចធ្វើឲ្យផលនៃគ្រាប់ពោត ធ្លាក់ចុះ និងបាត់បង់

គុណភាព ដោយសារទឹកភ្លៀងជ្រាបចូលក្នុងផ្លែ បណ្ដាលឲ្យគ្រាប់ដុះ ឬកើតជំងឺផ្សិតលើគ្រាប់។





## ការទុកដាក់ក្រោយពេលប្រមូលផល

ជាមធ្យមសំណើមគ្រាប់ក្រោយពេលប្រមូលផលគឺពី ១៨-២០% ដូច្នេះតម្រូវឲ្យយើងធ្វើការហាលសម្ងួតបន្ថែមទៀតដោយកំដៅថ្ងៃ។ ត្រូវឧស្សាហ៍ប្រែត្រឡប់គ្រាប់ខណៈកំពុងហាល ដើម្បីឲ្យគ្រាប់ឆាប់ស្ងួតល្អ។ ការយឺតយ៉ាវក្នុងការហាលសម្ងួត និងទុកដាក់គ្រាប់ពោតមិនបានល្អក្រោយពេលប្រមូលផល អាចធ្វើឲ្យកកើតសត្វល្អិតចង្រៃ ដូចជាខ្មូតជាដើម ដែលវាស៊ីបំផ្លាញគ្រាប់ពោតតាំងពីនៅលើដើម រហូតដល់គ្រាប់នៅក្នុងកន្លែងរក្សាទុកគ្រាប់ពូជ។ មិនតែប៉ុណ្ណោះ អាចធ្វើឲ្យបាត់បង់គុណភាព ដូចជាគ្រាប់កើតជំងឺផ្សិតធ្យូង គ្រាប់ឡើងផ្អូរដែលជាហេតុធ្វើឲ្យតម្លៃគ្រាប់ពោតធ្លាក់ចុះ។

## ការរក្សាទុកគ្រាប់

ពូជពោត "**សជ័យ**" ជាពូជដែលអាចរក្សាគ្រាប់ពូជទុកដាំដុះនៅរដូវបន្ទាប់ទៀតបាន មិនដូចពូជពោតអ៊ីប្រីដទេ ប្រសិនបើយើងដាំដុះវានៅដាច់តែឯងគ្មានពូជពោតផ្សេងនៅក្បែរ។ ការរក្សាគ្រាប់ពូជទុកសម្រាប់ប្រើនៅរដូវបន្ទាប់ ត្រូវមានសំណើមពី ១៣-១៥% គឺទុកនៅកន្លែងស្ងួតល្អ ឬរក្សាទុកក្នុងធុងបិទជិត ឬអាចទុកដាក់ដោយប្រើប្រាស់ថ្នាំការពារសត្វល្អិត។







រៀបចំដោយ ការិយាល័យរុក្ខជម្រើសវិទ្យា
វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (CARDI)